# មេរៀនទី ២៩: អ័ដាមនិងអេវ៉ាប្រព្រឹត្តអំពើបាប

## លោកុប្បត្តិ ៣

**គោលបំណង៖** ព្រះជាម្ចាស់ទ្រង់បរិសុទ្ធ ហើយព្រះអង្គមិនចង់ឱ្យយើងប្រព្រឹត្តអំពើបាបនោះទេ។

**ខគម្ពីរចងចាំ៖ រ៉ូម ៦:២៣** *"ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញគឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ព្រះជាម្ចាស់ទ្រង់ពិតជាអស្ចារ្យណាស់។ ទ្រង់យាងមករកយើង ហើយទ្រង់ស្រឡាញ់យើងរាល់គ្នា បើទោះបីជាយើងបានក្បត់នឹងទ្រង់ក្តី។ ព្រះអង្គបានផ្តល់ឱ្យយើងនូវការអត់ទោស និងជីវិតអស់កល្បតាមរយៈការសុគតរបស់ព្រះយេស៊ូវ។ តើអ្នកមានការតតាំងជាមួយនឹងអំពើបាបដែរឬទេ? ហើយតើអ្នកទទួលបានលទ្ធផលយ៉ាងណាដែរ? ព្រះជាម្ចាស់បានផ្តល់ឱ្យយើងនូវគម្រូក្នុងការដើរតាម និង ជាប្រភពនៃកម្លាំង ហើយជួយយើងឱ្យធ្វើការដោយនៅក្នុងព្រះនាមព្រះយេស៊ូវ។ ដែលទ្រង់បានជួយយើងឱ្យស្មោះត្រង់ជាមួយព្រះជាម្ចាស់។ ព្រះយេស៊ូវទ្រង់ជួយយើងឱ្យរួចពីអំពើបាប និងឱ្យយើងធ្វើជាសិស្សស្មោះត្រង់ក្នុងការដើរតាមបញ្ញត្តិរបស់ព្រះ។ ព្រះយេស៊ូវទ្រង់ជាថ្មដា និងជាកម្លាំងដែលជួយឱ្យយើងអាចយកឈ្នះលើអំពើបាបបាន។

**ចំរៀង៖** ១. ខ្ញុំសប្បាយរីករាយ ២.មានភ្នែកសម្រាប់មើលគម្ពីរ ៣. ព្រះយេស៊ូវមករកមនុស្សមានបាប

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ធ្វើតាមអ្នកដឹកនាំ»**



១. ឲ្យកុមារឈរជាជួរ ហើយបែរមុខទៅជញ្ជាំង

២. គ្រូនឹងទះស្មាកុមារនៅខាងក្រោយគេថ្មមៗ ហើយនឹងបង្ហាញកាយវិការមួយចំនួនទៅកាន់ពួកគេ ( ជិះម៉ូតូ ស្ទូងស្រូវ ។ល។)

៣. បន្ទាប់មកកុមារត្រូវទះស្មាកុមារបន្ទាប់ថ្មមៗ ឲ្យបែរមុខមកហើយបង្ហាញកាយវិការដែលគ្រូបានប្រាប់គេនោះ។ បន្តលេងល្បែងនេះរហូតដល់កុមារខាងមុខគេ។

៤. បន្ទាប់មកគ្រូនឹងហៅកុមារមុខគេ និងចុងក្រោយគេឲ្យមកបង្ហាញកាយវិការនោះព្រមគ្នា។ ប្រសិនបើពួកគេធ្វើកាយវិការដូចគ្នា នោះគេនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាកុមារម្នាក់ៗត្រូវដើរតាមអ្នកដឹកនាំ នោះព្រះចង់ឲ្យយើងដើរតាមមាគ៌ារបស់ទ្រង់។ ពេលយើងមិនដើរតាមមាគ៌ារបស់ព្រះអង្គ យើងនឹងប្រព្រឹត្តអំពើបាប។ ព្រះគឺបរិសុទ្ធហើយមិនចង់ឲ្យយើងធ្វើបាប ដូច្នេះយើងត្រូវតែដើរតាមមាគ៌ារបស់ព្រះជានិច្ច។

## ៤. ការណែនាំមេរៀន

ប្រសិនបើមានអ្នកណាម្នាក់ឱ្យស្ករគ្រាប់ពណ៌ខៀវ១០០០គ្រាប់មកអ្នក តែគេបានប្រាប់អ្នកថា អ្នកអាចយកស្ករ-គ្រាប់ ១០០០ គ្រាប់នេះបាន ប៉ុន្តែអ្នកមិនត្រូវញ៉ាំស្ករគ្រាប់ពណ៌ក្រហមមួយគ្រាប់នេះទេ។ តើអ្នកនឹងធ្វើដូចម្ដេច? តើអ្នកនឹងមិនញ៉ាំស្ករគ្រាប់ ១ គ្រាប់ ហើយជ្រើសរើសយកស្ករគ្រាប់ទាំង ១០០០ គ្រាប់ ឬអ្នកសុខចិត្តយកស្ករ-គ្រាប់ ១ គ្រាប់ជាជាង ១០០០ គ្រាប់នោះ? តើមួយណាជាជម្រើសដ៏ល្អបំផុត? ថ្ងៃនេះ យើងនឹងរៀនពីអ័ដាម និង អេវ៉ាដែលពួកគេមិនបានធ្វើការជ្រើសរើសបានត្រឹមត្រូវ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អ័ដាម និងអេវ៉ាគឺជាមនុស្សដំបូងបំផុតដែលបានរស់នៅក្នុងភពផែនដីនេះ។ នៅពេលដែលព្រះបង្កើតអ័ដាម និង អេវ៉ា ព្រះអង្គបានបង្កើតពួកគេដោយមិនមានបាបអ្វីសោះ។ ព្រះបានបង្កើតនិងឱ្យពួកគេរស់នៅក្នុងសួនច្បារដ៏ស្រស់ស្អាតមួយឈ្មោះសួនច្បារអេដែន។ អ្វីៗគ្រប់យ៉ាងនៅក្នុងសួនច្បារអេដែនគឺ ស្រស់ស្អាត និងល្អទាំងអស់ ហើយទាំងអ័ដាម និង អេវ៉ាពិតជារីករាយណាស់ ពីព្រោះនៅក្នុងសួននោះមានអ្វីគ្រប់យ៉ាងដែលពួកគេត្រូវការ។

មានដើមឈើ និង ផ្លែឈើរាប់ពាន់ប្រភេទនៅក្នុងសួន ហើយព្រះបានប្រាប់អ័ដាមថាគាត់អាចញ៉ាំផ្លែឈើណាក៏បាននៅក្នុងសួននោះ។ ប៉ុន្តែព្រះបានប្រាប់អ័ដាមថាគាត់មិនត្រូវចូលទៅជិតដើមឈើតែមួយដើមគត់ដែលមានឈ្មោះថាជាដើមដឹងខុសត្រូវទេ។ ព្រះបានប្រាប់ពួកគេថា ពួកគេនឹងស្លាប់បើពួកគេញ៉ាំផ្លែដឹងខុសត្រូវនោះ។

ថ្ងៃមួយមានពស់មួយក្បាលបានមកល្បួងអេវ៉ា ដោយនិយាយថា “មើលផ្លែឈើនៅលើដើមនោះស្អាតយ៉ាងណា! ហើយហេតុអ្វីអ្នកមិនសាកញ៉ាំវាមើល? វាច្បាស់ជាឆ្ងាញ់ណាស់។ កុំស្ដាប់តាមព្រះអី! ញ៉ាំវាចុះ វានឹងមិនអីទេ!” តើអេវ៉ាគួរតែញ៉ាំផ្លែឈើនោះទេ? អត់ទេ! ប៉ុន្តែអេវ៉ាចង់ញ៉ាំវា ពីព្រោះវាមើលទៅគួរឱ្យឆ្ងាញ់ណាស់។ បើទោះបីជាព្រះជាម្ចាស់ទ្រង់ហាមនាងមិនឱ្យបរិភោគផ្លែនោះក៏ដោយក៏នាងនៅតែញ៉ាំផ្លែឈើនោះដែរ។ ហើយនាងក៏បានឱ្យអ័ដាមញ៉ាំផងដែរ។ អ័ដាមដឹងថាព្រះបានហាមគាត់មិនឱ្យញ៉ាំផ្លែនោះ ប៉ុន្តែគាត់ក៏នៅតែញ៉ាំវាដដែល។

ក្រោយមកព្រះក៏បានសួរដល់អ័ដាមថា “តើឯងបានស៊ីផ្លែឈើដែលអញហាមមិនឲ្យស៊ីឬអី?” នោះអ័ដាម និង អេវ៉ាក៏បានឆ្លើយថាពួកគេពិតជាបានញ៉ាំផ្លែឈើនោះមែន។ ព្រះមិនសប្បាយព្រះទ័យនោះទេ ទ្រង់បានមានបន្ទូលថា “ដោយព្រោះឯងមិនស្ដាប់បង្គាប់យើង ពួកឯងត្រូវបាននិរទេសចេញពីសួនច្បាររបស់យើងហើយ”។ ថ្ងៃដែលអ័ដាម និង អេវ៉ាចាកចេញពីសួនច្បារដ៏ស្រស់ស្អាតរបស់ព្រះជាម្ចាស់នោះ គឺជាថ្ងៃដ៏សោកសៅបំផុត។ ពួកគេពិតជាមានការសោកស្ដាយជាខ្លាំងដែលពួកគេមិនបានធ្វើតាមបង្គាប់ព្រះ។

ព្រះជាម្ចាស់ទ្រង់បរិសុទ្ធ ហើយទ្រង់មិនចង់ឱ្យយើងមាននូវអំពើបាបនោះទេ។ នៅពេលដែលយើងនិយាយថាព្រះបរិសុទ្ធ គឺមានន័យថាទ្រង់គឺល្អឥតខ្ចោះ ហើយទ្រង់គឺស្អាតបរិសុទ្ធ។ ប្រសិនបើយើងមិនធ្វើអ្វីខុសទាល់តែសោះនោះគឺមានន័យថាយើងគឺបរិសុទ្ធហើយ។ ប៉ុន្តែនៅពេលដែលយើងប្រព្រឹត្តកំហុសដូចជា អ័ដាម និង អេវ៉ាបានធ្វើនោះ គឺមានន័យថាយើងមានបាបហើយ។ ព្រះជាម្ចាស់ទ្រង់មិនមានបាបនោះទេ ប៉ុន្តែយើងរាល់គ្នាគឺសុទ្ធតែមានបាប។

ព្រះដ៏បរិសុទ្ធទ្រង់អាចសម្រេចព្រះទ័យថាទ្រង់មិនចង់មានទំនាក់ទំនងជាមួយនឹងមនុស្សយើងដោយព្រោះតែអំពើបាបរបស់យើងក៏បាន។ ប៉ុន្តែដោយព្រោះទ្រង់ស្រឡាញ់យើង ទើបធ្វើឱ្យទ្រង់មានផែនការក្នុងការសំអាតនូវអំពើបាបរបស់យើង។ ការអត់ទោសរបស់ទ្រង់គឺជួយឱ្យយើងបានស្អាត។ នៅពេលដែលព្រះអត់ទោសយើង គឺមានន័យថាយើងត្រូវបានកើតជាថ្មី និងបានស្អាតផងដែរ។ ព្រះបានអត់ទោសដល់អ័ដាម និង អេវ៉ា ហើយទ្រង់ក៏បានអត់ទោសដល់យើងដូចគ្នាដែរ។ ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវដើម្បីឱ្យយើងរាល់គ្នាត្រូវបានទទួលនូវការអត់ទោស។ នៅពេលដែលយើងជឿលើព្រះយេស៊ូវ គឺទ្រង់បានអត់ទោសដល់អំពើបាបរបស់យើងហើយ! សូមឱ្យយើងបានបែរចេញពីអំពើបាប ហើយបានបរិសុទ្ធពីព្រោះព្រះនៃយើងទ្រង់បរិសុទ្ធ!

## ៦. សំនួរពិភាក្សា

១. តើសួនច្បារដែលព្រះបានដាក់អ័ដាម និង អេវ៉ាឱ្យនៅនោះមានឈ្មោះអ្វី? *សួនច្បារអេដែន*

២. ហេតុអ្វីបានជាយើងគិតថាសួនច្បារនោះជាកន្លែងដ៏អស្ចារ្យដែលគួរឱ្យចង់រស់នៅ?
*អ័ដាម និង អេវ៉ា មានអ្វីគ្រប់យ៉ាងដែលពួកគេត្រូវការ*

៣. តើដើមឈើអ្វីដែលព្រះបានហាមមិនឱ្យអ័ដាមនិងអេវ៉ាញ៉ាំផ្លែវានោះ? *ដើមផ្លែដឹងខុសត្រូវ*

៤. តើមូលហេតុអ្វីដែលធ្វើឱ្យអ័ដាម និង អេវ៉ាបានញ៉ាំផ្លែដឹងខុសត្រូវនោះ? *ពីព្រោះសត្វពស់បានល្បួងពួកគេ, ពីព្រោះពួកគេមិនទុកចិត្តព្រះ, ពីព្រោះពួកគេគិតថាពួកគេដឹងច្រើនជាងព្រះ*

៥. តើអ្នកអាចរក្សាខ្លួនអ្នកឱ្យនៅឆ្ងាយពីអំពើបាបបានយ៉ាងដូចម្ដេច? *ទុកឱ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ជ្រើសរើសពណ៌»

**សម្ភារៈដែលត្រូវការ៖** ខ្មៅដៃពណ៌ ៣ ដើម




១. ចែកកុមារជា ៣ក្រុម

២. គ្រូនឹងសុំឲ្យគ្រូជំនួយ ៣នាក់លាក់ ខ្មៅដៃនោះម្នាក់មួយ

៣. នៅពេលដែលគ្រូនិយាយពណ៌ណាមួយក្នុងចំណោមពណ៌ទាំងបី ក្រុមនីមួយៗត្រូវពិភាក្សាគ្នាថា តើជំនួយការគ្រូណាមួយមានពណ៌របស់ខ្មៅដៃដែលគ្រូបាននិយាយនោះ ហើយនាំគ្នាទៅឈរនៅពីមុខគ្រូជំនួយនោះ។

៤. ប្រសិនបើក្រុមណាមួយធ្វើការជ្រើសបានត្រឹមត្រូវ នោះក្រុមរបស់គេនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងតែងតែធ្វើការជ្រើសរើសនៅក្នុងជីវិត។ វាគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជ្រើសរើសដើរតាមផ្លូវរបស់ព្រះនៅគ្រប់ការទាំងអស់ដែលយើងធ្វើនោះ ពីព្រោះព្រះគឺបរិសុទ្ធហើយព្រះអង្គមិនចង់ឲ្យយើងធ្វើអំពើបាបនោះទេ។

## ៨. ខគម្ពីរចងចាំ រ៉ូម ៦:២៣

## ៩. ហត្ថកម្ម « អ័ដាមនិងអេវ៉ាប្រព្រឹត្តអំពើបាប »




**សំភារៈដែលត្រូវការ៖** សូមបោះពុម្ពក្រដាសហត្ថកម្ម កូល័រទៀន កន្ត្រៃ និង ការបិត

១. សូមចែកក្រដាសហត្ថកម្មទៅកុមារម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌

២. កាត់រូប អ័ដាម អេវ៉ា ពស់ និងផ្លែដឹងខុសត្រូវចេញមករួចបិតរូបទាំងនោះទៅតាមកន្លែងដែលត្រឹមត្រូវ

៣. ពន្យល់កុមារថា ព្រះទ្រង់បរិសុទ្ធ ហើយទ្រង់មិនចង់ឱ្យយើងមានបាបនោះទេ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# អ័ដាមនិងអេវ៉ាប្រព្រឹត្តអំពើបាប





សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសហាត្ថកម្ម កូល័រទៀន កន្ត្រៃ និង ការបិត

១. សូមចែកក្រដាសហាត្ថកម្មទៅកុមារម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌

២. កាត់រូប អ័ដាម អេវ៉ា ពស់ និងផ្លែដឹងខុសត្រូវ ចេញមក រួចបិតរូបទាំងនោះទៅតាមកន្លែងដែលត្រឹមត្រូវ

៣. ពន្យល់កុមារថា ព្រះទ្រង់បរិសុទ្ធ ហើយទ្រង់មិនចង់ឱ្យយើងមានបាបនោះទេ។